**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ១៤៣៨ មស.នក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៦

**សូមគោរពជូន**
**សម្តេចចៅហ្វាវាំង សម្តេចក្រឡាហោម ឯកឧត្តម លោកជំទាវ**
**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** : ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា។

**យោង** : - ព្រះរាជក្រមលេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- អនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីរបបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា ដើម្បីចូលរួមគ្រប់គ្រងវត្តមានការងារពិតប្រាកដរបស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នទាំងអស់ មេត្តាជំរុញឱ្យប្រធានអង្គភាពគ្រប់គ្រងផ្ទាល់អនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និង មន្ត្រីជាប់កិច្ចសន្យានៅតាមអង្គភាពនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដូចមានយោងខាងលើ។

ក្នុងស្មារតីនេះ ក្រសួងមុខងារសាធារណៈ ស្នើដល់គ្រប់ក្រសួង ស្ថាប័ន មេត្តាចាត់ចែងនិងណែនាំដល់គ្រប់នាយកដ្ឋានបុគ្គលិក ឬ អង្គភាពគ្រប់គ្រងធនធានមនុស្សក្រោមឱវាទនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផ្តល់របាយការណ៍អំពីការដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានផ្អែកលើបទបញ្ញត្តិនៃអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា មកអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ ឱ្យបានត្រឹមថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦។

ក្នុងករណី ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានជួបបញ្ហាប្រឈមក្នុងការអនុវត្តខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តដូចមានយោងខាងលើ ឬមានសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាលបន្ថែម ឬត្រូវការព័ត៌មានបន្ថែម ថ្នាក់ដឹកនាំនិងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិកនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាចទំនាក់ទំនងមកនាយកដ្ឋាននីតិកម្ម និង វិវាទមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ តាមរយៈលោកស្រី តឹក កុសុនា លេខទូរស័ព្ទ ០១៧ ៤៥១ ៤៥៦ ឬ លោក ហែន សារិទ្ធ លេខទូរស័ព្ទ ០១៧ ២២៨ ៨២៨ ដើម្បីដោះស្រាយនិងមានចំណាត់ការទាន់ពេលវេលា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចចៅហ្វាវាំង សម្តេចក្រឡាហោម ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបនិងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ